# ការយល់ដឹងពីជំងឺរលាកថ្លើមប្រភេទ B

## តើខ្ញុំត្រូវដឹងអ្វីខ្លះ ?



Cambodian

GILEAD

hepBsmart.com

# សូមស្វាគមន៍

ជំងឺរលាកថ្លើប្រភេទ B (ឬ hep B)គឺជាជំងឺថ្លើមធ្ងន់ធ្ងរដែលប៉ះពាល់មនុស្សរាប់លាននាក់ទូទាំងពិភពលោក។

កូនសៀវភៅ មានបំណងជួយលោកអ្នកឲ្យយល់ដឹងកាន់តែប្រសើរអំពីជំងឺរលាកថ្លើមប្រភេទ B ហើយរៀនសូត្រអំពីរបៀបគ្រប់គ្រងជំងឺនេះ។

## នៅខាងក្នុងកូនសៀវភៅនេះ យើងនឹងស្វែងយល់អំពីប្រធានបទ ដូចខាងក្រោម៖

- របៀបដែលជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃប៉ះពាល់ដល់សុខភាពថ្លើម
- របៀបដែលជំងឺរលាកថ្លើមប្រភេទ B ឆ្លង
- ការធ្វើតេស្ត និងការចាក់ថ្នាំបង្ការ
- របៀបដែលជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ត្រូវបានព្យាបាល

## សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត សូមចូលទៅគេហទំព័រ **HEPBSMART.COM®**

# តើជំងឺរលាកថ្លើមប្រភេទ B ជាជំងឺអ្វី?

## ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺថ្លើមទូទៅបំផុតនៅលើពិភពលោក

ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺធ្ងន់ធ្ងរ និងអាចបណ្ដាលឲ្យស្លាប់បាត់បង់ជីវិត។ ជំងឺនេះបង្កឡើងដោយសារមេរោគជំងឺរលាកថ្លើមប្រភេទ B (HBV)។



## តើអ្វីនឹងកើតឡើងប្រសិនបើខ្ញុំមានមេរោគជំងឺរលាកថ្លើមប្រភេទ B ?

នៅពេលមនុស្សម្នាក់បានឆ្លងមេរោគនេះជាលើកដំបូង ជំងឺនេះ គេហៅថា ជំងឺ**ធ្ងន់ធ្ងរ**។




ប៉ុន្តែ ប្រសិនបើមនុស្សម្នាក់មានជំងឺរលាកថ្លើមប្រភេទ B លើសពី 6 ខែ ជំងឺនេះគេហៅថា ជំងឺរលាកថ្លើមប្រភេទ B **រ៉ាំរ៉ៃ**។

### មនុស្សភាគច្រើន ដែលមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ពុំមានរោគសញ្ញាទេ ហើយមានសុខភាពល្អធម្មតា។ ប៉ុន្តែ៖

- គេអាចរងការខូចខាតថ្លើមរួចហើយ
- គេនៅតែអាចចម្លងទៅអ្នកដទៃទៀតបាន

**ជាការសំខាន់ណាស់ ត្រូវដឹងពីស្ថានភាពនៃជំងឺរលាកថ្លើមប្រភេទ B របស់លោកអ្នក ព្រោះវានឹងជួយលោកអ្នកឲ្យយល់ដឹងកាន់តែប្រសើរអំពីរបៀបថែទាំសុខភាពថ្លើមរបស់លោកអ្នក**

## តើថ្លើមខ្ញុំធ្វើកិច្ចការអ្វីខ្លះ ?

### ថ្លើមគឺជាសរីរាង្គសំខាន់ ដែលលោកអ្នកមិនអាចរស់នៅ ដោយគ្មានវាបាន

**ថ្លើមជាសរីរាង្គធំបំផុតក្នុងខ្លួនប្រាណ ហើយថ្លើមបំពេញមុខងារដូចខាងក្រោម៖**



ប្រែក្លាយចំណីដែលយើងបានហូប និងផឹក ឲ្យទៅជាថាមពល និងសារធាតុចិញ្ចឹម



លាងសម្អាតសារធាតុគីមីដែលបង្កគ្រោះថ្នាក់ ចេញពីឈាមរបស់លោកអ្នក



ប្រយុទ្ធប្រឆាំងនឹងការឆ្លងជំងឺ



បង្កើតសារធាតុ ដែលជួយរំលាយអាហារ

hepB smart.com ជាមួយនឹង GILEAD

# តើជំងឺរលាក់ថ្លើមប្រភេទ B រ៉ាំរ៉ៃ ប៉ះពាល់ដល់ថ្លើមដោយរបៀបណា ?

## ជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ អាចបង្កការខូចខាត ដោយអ្នកមិនបានដឹងខ្លួន

ពេលខ្លះ ជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ត្រូវបានគេហៅថាជា **"ឃាតករស្ងប់ស្ងៀម"** ព្រោះ បើទោះបីជាលោកអ្នកមិនមានអារម្មណ៍ឈឺក៏ដោយ ប៉ុន្តែ វាអាចបង្កឲ្យខូចខាតថ្លើម ដូចជា៖



### រលាកថ្លើម



### ហ្វីប្រូស៊ីស

ធ្វើឲ្យថ្លើមមានសម្លាក



### ជំងឺក្រិនថ្លើម

សម្លាកធ្ងន់ធ្ងរ ដែលអាចប៉ះពាល់ដល់មុខងារថ្លើមរបស់លោកអ្នក



### ជំងឺមហារីកថ្លើម

ជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ គឺជាមូលហេតុចម្បងដែលបង្កជំងឺមហារីកថ្លើម

ប្រសិនបើទុកចោលមិនព្យាបាល មនុស្ស **1 នាក់នៃ 4 នាក់** ដែលមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ កើតបញ្ហាថ្លើម ដូចជា ជំងឺក្រិនថ្លើម និងជំងឺមហារីកថ្លើម។






ការថែទាំខ្លួនឯង អាចមានអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែ ប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ការថែទាំដោយខ្លួនឯងអាចមិនគ្រប់គ្រាន់ឡើយ។




វេជ្ជបណ្ឌិតរបស់អ្នកអាចកំណត់ថាតើអ្នកមានសិទ្ធិទទួលបានការព្យាបាលជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ឬយ៉ាងណា។

**ប្រសិនបើលោកអ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ សូមពិភាក្សាជាមួយនឹងវេជ្ជបណ្ឌិតរបស់លោកអ្នក អំពីថាតើ លោកអ្នកអាចធ្វើអ្វីខ្លះបាន ដើម្បីគ្រប់គ្រងជំងឺនេះ**

# តើជំងឺរលាកថ្លើមប្រភេទ B ឆ្លងរាលដាល ដោយរបៀបណា?

## **វិធីតែមួយគត់** ដែលឆ្លងមេរោគជំងឺរលាកថ្លើម ប្រភេទ B គឺការប៉ះពាល់ឈាម ឬវត្ថុរាវនៃខ្លួនប្រាណ ដែលមានមេរោគ

### លោកអ្នក **អាច** ឆ្លងមេរោគនេះ ពី៖



- ម្តាយរបស់លោកអ្នក បើគាត់មានជំងឺរលាកថ្លើមប្រភេទ B នៅពេលលោកអ្នកកើត (ទូទៅបំផុត)
- ឈាមដែលមានមេរោគ បន្ទាប់ពីរបួស ការខាំ ឬស្នាមរលាត់ស្បែក
- ការដោះដូរវត្ថុរាវនៃខ្លួនប្រាណ ក្នុងអំឡុងពេលរួមភេទ
- ការប្រើម្ជុលដែលពុំបានសម្លាប់មេរោគរួមគ្នា (រួមទាំងម្ជុលសាក់ ឬគ្រឿងចាក់ខ្លួនប្រាណ)

### លោកអ្នកអាច **មិនដែល** ឆ្លងមេរោគនេះ ពី៖



- ការប៉ះពាល់
- ការថើប
- ការផឹកគ្រឿងស្រវឹង
- ចំណីអាហារ ទឹក ឬខ្យល់
- ការប្រើពែង និងសមស្លាបព្រារួមគ្នា

**ដឹងពីរបៀប មេរោគជំងឺរលាកថ្លើមប្រភេទ B ឆ្លង អាចជួយបង្ការលោកអ្នក និងគ្រួសារលោកអ្នក កុំឲ្យឆ្លងមេរោគ។**

hepB smart.com
ជាមួយនឹង GILEAD

# តើខ្ញុំអាចមានហានិភ័យដែរឬទេ ?

## ដោយសារតែជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺថ្លើមសាមញ្ញមួយ ដូច្នេះ មនុស្សជាច្រើននាក់ មានហានិភ័យ

**មនុស្សរហូតដល់**

**2 លាន**

**នាក់បានឆ្លងជំងឺនេះ នៅសហរដ្ឋអាមេរិក។**

- មនុស្ស 2 នាក់ ក្នុងចំណោម 3 នាក់ ដែលមានជំងឺរលាកថ្លើមប្រភេទ B ពុំដឹងខ្លួនទេថា ពួកគេមានជំងឺនេះ
- មនុស្សចំនួន 240 លាននាក់ បានឆ្លងជំងឺនេះ ទូទាំងពិភពលោក
- រាល់ឆ្នាំ មានករណីមនុស្សស្លាប់ប្រមាណ 786,000 នាក់ ដែលពាក់ព័ន្ធនឹងជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ទូទាំងពិភពលោក

## លោកអ្នកកើតនៅតំបន់ ដែលគូសពណ៌ក្រហម មានហានិភ័យខ្ពស់ *ក្នុងការឆ្លងជំងឺរលាកថ្លើមប្រភេទ B




*ហានិភ័យខ្ពស់៖ ≥2% នៃប្រជាជន ដែលមានជំងឺរលាកថ្លើមប្រភេទ B។

## ជាការសំខាន់ ត្រូវយល់ដឹងពីកត្តាហានិភ័យនៃជំងឺរលាកថ្លើមប្រភេទ B

**កត្តាហានិភ័យបន្ថែមមួយចំនួន រួមបញ្ចូល៖**

- កើតនៅសហរដ្ឋអាមេរិក ដោយមិនបានចាក់ថ្នាំវ៉ាក់សាំងពេលនៅជាទារក ហើយមានឪពុកម្ដាយដែលកើតនៅក្នុងបណ្ដាប្រទេសមានហានិភ័យខ្ពស់
- បានធ្វើដំណើរទៅកាន់បណ្ដាប្រទេស ដែលកើតជំងឺរលាកថ្លើមប្រភេទ B ជាទូទៅ
- ចាប់កំណើតពីផ្ទៃម្ដាយ ដែលមានជំងឺរលាកថ្លើមប្រភេទ B
- ប៉ះពាល់វត្ថុរាវខ្លួនប្រាណ ដែលមានមេរោគជំងឺរលាកថ្លើមប្រភេទ B (ឈាម ទឹកកាម ឬទឹកយោនី)
- រួមភេទជាមួយនឹងអ្នកមានជំងឺរលាកថ្លើមប្រភេទ B ដោយគ្មានការការពារ
- បានចាក់សាក់ ឬចោះលើខ្លួនប្រាណ ជាមួយនឹងឧបករណ៍ដែលពុំបានសម្លាប់មេរោគ
- ប្រើម្ជុលដែលពុំបានសម្លាប់មេរោគរួមគ្នា

**ការយល់ដឹងពីហានិភ័យទាំងនេះ អាចជួយលោកអ្នកការពារខ្លួនលោកអ្នក គ្រួសារ និងមិត្ត របស់លោកអ្នក កុំឲ្យឆ្លងជំងឺរលាកថ្លើមប្រភេទ B**

# តើខ្ញុំអាចប្រាប់បានយ៉ាងដូចម្តេច បើ ខ្ញុំមានជំងឺរលាកថ្លើមប្រភេទ B ?

## ការធ្វើតេស្តឈាមធម្មតា នឹងប្រាប់បានថាតើខ្ញុំមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ឬអត់៖



ឈាមត្រូវបូមពីសរសៃឈាមលើដៃរបស់លោកអ្នក



ឈាមត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍ដើម្បីពិនិត្យ

**គ្រប់គ្រងលើសុខភាពរបស់លោកអ្នក និងជួបពិភាក្សាជាមួយនឹងវេជ្ជបណ្ឌិតរបស់លោកអ្នក អំពីការធ្វើតេស្តឈាម**

# តើលទ្ធផលតេស្តមានអត្ថន័យអ្វីខ្លះ ?

លទ្ធផលនៃតេស្តឈាមរបស់លោកអ្នក នឹងជួយប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នកថាតើ លោកអ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬអត់ ឬថាតើ លោកអ្នកត្រូវបានការពាររួចហើយពីជំងឺរលាកថ្លើមប្រភេទ B ឬអត់។

**លទ្ធផលតេស្តប្រហែលមាន 3 ប្រភេទ៖**

### មានហានិភ័យ



លោកអ្នកមិនដែលមានជំងឺរលាកថ្លើមប្រភេទ B ទេ ឬមិនដែលបានចាក់ថ្នាំវ៉ាកសាំងទេ។ **លោកអ្នកគួរទៅចាក់ថ្នាំវ៉ាក់សាំង។**

### បានឆ្លងរួចហើយ



លោកអ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ។ **សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នកថា តើ លោកអ្នកត្រូវការការព្យាបាល ឬអត់។**

### មានការការពារ



លោកអ្នកមានវ៉ាក់សាំងហើយ ឬលោកអ្នកមានជំងឺរលាកថ្លើមប្រភេទ B ពីមុន ហើយខ្លួនប្រាណរបស់លោកអ្នកបានកម្ចាត់វាអស់ហើយ។ **សូមលើកទឹកចិត្តអ្នកជាទីស្រឡាញ់របស់លោកអ្នក ឲ្យទៅធ្វើតេស្តឈាម។**

hep B smart .com
ជាមួយនឹង GILEAD

# តើថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B គឺជាអ្វី?

## ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B មានសុវត្ថិភាព និងប្រសិទ្ធិភាព ក្នុងការបង្ការការឆ្លងជំងឺរលាកថ្លើមប្រភេទ B

មានថ្នាំវ៉ាក់សាំង ដូចខាងក្រោម៖

**ថ្នាំចាក់ពីរដង** ដែលចាក់ម្តងមួយខែ ឬ **ថ្នាំចាក់បីដង** ដែលចាក់ម្តងមួយខែ ហើយថ្នាំចាក់លើកទីបី ត្រូវចាក់ 4 ខែក្រោយមក




ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីថាតើថ្នាំវ៉ាក់សាំងមួយណាដែល ល្អ ប្រសើរបំផុតសម្រាប់អ្នក។

**ត្រូវចងចាំថា ជាការសំខាន់ដែលអ្នក ត្រូវចាក់ថ្នាំវ៉ាក់សាំងទាំងអស់របស់អ្នក ដើម្បីការពារប្រឆាំងនឹងមេរោគ។**

## ជាការសំខាន់ ត្រូវដឹងពីព័ត៌មានពិតនៃថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B



ថ្នាំវ៉ាក់សាំង**មិន**មានប្រសិទ្ធភាពចំពោះលោកអ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B រួចហើយឡើយ



លោកអ្នក**មិន**អាចឆ្លងជំងឺរលាកថ្លើមប្រភេទ B ពីថ្នាំវ៉ាក់សាំងទេ ព្រោះថ្នាំវ៉ាក់សាំងពុំមានមេរោគនៅរស់ទេ។

**ប្រសិនបើលោកអ្នកគ្មានជំងឺរលាកថ្លើមប្រភេទ B និងមិនបានចាក់ថ្នាំវ៉ាក់សាំង សូមពិភាក្សាជាមួយនឹងវេជ្ជបណ្ឌិតរបស់លោកអ្នកអំពីការចាក់ថ្នាំវ៉ាក់សាំង ហើយលើកទឹកចិត្តមិត្ត និងគ្រួសាររបស់លោកអ្នកឲ្យចាក់ថ្នាំវ៉ាក់សាំងផងដែរ**



hepB smart.com
ជាមួយនឹង GILEAD

## ប្រសិនបើខ្ញុំមានជំងឺរលាកថ្លើមប្រភេទ B តើខ្ញុំអាចធ្វើអ្វីខ្លះបាន ?

### បើទោះបីជាលោកអ្នកមានអារម្មណ៍ធម្មតា លោកអ្នកមិនអាចប្រងើយកន្តើយចំពោះជំងឺរលាកថ្លើមប្រភេទ B របស់លោកអ្នកឡើយ

លោកអ្នកអាចគ្រប់គ្រងជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃរបស់លោកអ្នកបាន ជាមួយនឹងការគាំទ្រពីវេជ្ជបណ្ឌិត គ្រួសារ និងមិត្តភ័ក្តិរបស់លោកអ្នក។

ការថែទាំខ្លួនឯង អាចមានអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែប្រសិនបើអ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ការថែទាំដោយខ្លួនឯងអាចមិនគ្រប់គ្រាន់ឡើយ។



**ជំហានទីមួយរបស់លោកអ្នក គឺត្រូវស្វែងរកវេជ្ជបណ្ឌិតម្នាក់ដែលលោកអ្នកទុកចិត្ត ហើយទៅជួបវេជ្ជបណ្ឌិតនោះជាប្រចាំ ដើម្បីឲ្យគាត់អាចតាមដានការវិវត្តន៍នៃសុខភាពរបស់លោកអ្នក**

វេជ្ជបណ្ឌិតរបស់អ្នកអាចកំណត់ថាតើអ្នកមានសិទ្ធិទទួលបានការព្យាបាលជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ឬយ៉ាង ណា។

## តើជំងឺរលាកថ្លើមប្រភេទ B អាចព្យាបាលបានដែរឬទេ ?

### ប្រសិនបើលោកអ្នកត្រូវបានធ្វើរោគវិនិច្ឆ័យឃើញមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចចេញវេជ្ជបញ្ជាសម្រាប់ថ្នាំប្រឆាំងមេរោគ

គោលដៅនៃការព្យាបាលដោយប្រើថ្នាំប្រឆាំងមេរោគ គឺដើម្បី៖



កាត់បន្ថយបរិមាណមេរោគជំងឺរលាកថ្លើមប្រភេទ B ក្នុងខ្លួនប្រាណរបស់លោកអ្នក



កាត់បន្ថយហានិភ័យនៃបញ្ហាថ្លើម ដូចជា ក្រិនថ្លើម ថ្លើមខូច និងជំងឺមហារីកថ្លើម

ថ្នាំប្រឆាំងមេរោគអាចជាថ្នាំគ្រាប់ ឬថ្នាំចាក់។ អ្នកជំងឺដែលប្រើថ្នាំទាំងនេះ ត្រូវតាមដានរកផលរំខាន ដោយអ្នកផ្តល់សេវាថែទាំសុខភាព។

**ផ្នែកសំខាន់នៃការគ្រប់គ្រងជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃរបស់លោកអ្នក គឺត្រូវសួរវេជ្ជបណ្ឌិតរបស់លោកអ្នកអំពីជម្រើសផ្សេងៗ ដែលជាជាជម្រើសនៃការព្យាបាល។**

# តើខ្ញុំគួរចងចាំអ្វីខ្លះអំពីជំងឺរលាកថ្លើម ប្រភេទ B រ៉ាំរ៉ៃ ?



ជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ គឺជាជំងឺថ្លើមទូទៅបំផុត ហើយអាចបង្កបញ្ហាថ្លើមធ្ងន់ធ្ងរ ដូចជាក្រិនថ្លើម និងជំងឺមហារីកថ្លើម



វិធីតែមួយគត់ ដែលឆ្លងជំងឺរលាកថ្លើមប្រភេទ B គឺតាមរយៈឈាម ឬវត្ថុរាវនៃខ្លួនប្រាណដែលមានមេរោគ។ តាមពិត មនុស្សភាគច្រើន ដែលមានជំងឺរលាកថ្លើមប្រភេទ B បានឆ្លងមេរោគនេះពេលចាប់កំណើត ប្រសិនបើម្តាយរបស់ពួកគេមានជំងឺរលាកថ្លើមប្រភេទ B



តេស្តឈាមធម្មតាអាចបង្ហាញថាតើ លោកអ្នកមានជំងឺរលាកថ្លើមប្រភេទ B ឬអត់ ឬថាតើ លោកអ្នកមានការការពារពីជំងឺនេះ ឬអត់



ប្រសិនបើលោកអ្នកមិនដែលឆ្លងជំងឺរលាកថ្លើមប្រភេទ B ទេ មានថ្នាំវ៉ាក់សាំងការពារ



ប្រសិនបើលោកអ្នកមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ជាការសំខាន់ត្រូវទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នកជាប្រចាំ



លោកអ្នកអាចមានអារម្មណ៍មានសុខភាពល្អ ប៉ុន្តែ លោកអ្នកនៅតែមានជំងឺរលាកថ្លើមប្រភេទ B ឬមានហានិភ័យងាយខូចថ្លើម



មានការព្យាបាល ដែលអាចជួយកាត់បន្ថយបរិមាណមេរោគក្នុងខ្លួនប្រាណរបស់លោកអ្នក ហើយអាចកាត់បន្ថយនូវហានិភ័យនៃបញ្ហាថ្លើម

***Gilead** ប្តេជ្ញាលើកកម្ពស់ការយល់ដឹង និងអប់រំពីជំងឺរលាកថ្លើមប្រភេទ **B** នៅក្នុងសហគមន៍*

hepB smart.com
ជាមួយនឹង GILEAD

# តើខ្ញុំគ្រប់គ្រងសុខភាពថ្លើមរបស់ខ្ញុំដោយរបៀបណា ?

**ដឹងពីស្ថានភាពជំងឺរលាកថ្លើមប្រភេទ B របស់លោកអ្នក**
ធ្វើតេស្ត និងជជែកជាមួយនឹងគ្រួសារ និងមិត្តរបស់លោកអ្នក អំពីការធ្វើតេស្តពិនិត្យរកជំងឺរលាកថ្លើមប្រភេទ B

**ប្រសិនបើលោកអ្នកគ្មានជំងឺរលាកថ្លើមប្រភេទ B ទេ**
ពិភាក្សាជាមួយនឹងវេជ្ជបណ្ឌិតរបស់លោកអ្នក អំពីការចាក់ថ្នាំវ៉ាក់សាំង និងលើកទឹកចិត្តអ្នកជាទីស្រឡាញ់របស់លោកអ្នក ឲ្យទៅចាក់ថ្នាំវ៉ាក់សាំងផងដែរ។

**ប្រសិនបើលោកអ្នកមានជំងឺរលាកថ្លើមប្រភេទ B**
មានការព្យាបាល ដែលអាចកាត់បន្ថយហានិភ័យខូចថ្លើមធ្ងន់ធ្ងរ។ សូមទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នកជាប្រចាំ ហើយពិភាក្សាអំពីជម្រើសផ្សេងៗ ដែលអាចជាជម្រើសនៃការព្យាបាល។

ការសិក្សាបន្ថែមអំពីជំងឺរលាកថ្លើមប្រភេទ B គឺជាផ្នែកសំខាន់មួយនៃការគ្រប់គ្រងលើសុខភាពថ្លើមរបស់លោកអ្នក។

សម្រាប់ព័ត៌មានបន្ថែមទៀត សូមចូលទស្សនាគេហទំព័រ **HEPBSMART.COM**®

GILEAD

hep B smart .com

GILEAD, GILEAD Logo, HEPBSMART, HEPBSMART.COM, HEPBSMART Logo និង Liver Icon គឺ ជា ពាណិជ្ជ សញ្ញា របស់ ក្រុម ហ៊ុន Gilead Sciences, Inc.
©2018 Gilead Sciences, Inc. រក្សាសិទ្ធិគ្រប់យ៉ាង
UNBC6036 09/18